# មេរៀនទី ៩៣៖ ដាវីឌមានចិត្តសប្បុរសចំពោះមេភីបូសែត

## ២សាំយូអែល ៩

**មេរៀន** (*យូធូបលីង*)៖ https://youtu.be/kfXaDQX42Kg

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/7ijW_uqu-C8

**គោលបំណង៖** ព្រះជាម្ចាស់មានព្រះទ័យសប្បុរស។

**ខគម្ពីរចងចាំ៖ ១ យ៉ូហាន៤៖១២** *"គ្មានអ្នកណាដែលឃើញព្រះឡើយ តែបើយើងស្រឡាញ់គ្នាទៅ វិញទៅមក នោះព្រះទ្រង់គង់នៅក្នុងយើង ហើយសេចក្តីស្រឡាញ់របស់ទ្រង់ បានពេញខ្នាតក្នុងយើងដែរ។"*

**ចំរៀង** (*យូធូបលីង*)៖

១. ព្រះយេស៊ូវល្អក្រៃលែង https://youtu.be/uFsMi06lhvE
២. ព្រះអម្ចាស់យើងល្អណាស់ https://youtu.be/JUMy8rZvqjY
៣. ព្រះនឹងរៀបចំផ្លូវ https://youtu.be/pKmid-FNhhw

### ១. អធិស្ឋាន

### ២. ចំរៀង (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

### ៣. ល្បែងកំសាន្ត «បញ្ចុកចេក»

សម្ភារៈដែលត្រូវការ៖ ផ្លែចេក និងក្រមា ឬម៉ាស



១. ចែកកុមារជា៤ក្រុម កុមារឈរជាជួរទល់មុខគ្នា ក្រុមទី១ទល់មុខក្រុមទី២ ហើយក្រុម៣ទល់មុខក្រុមទី៤ (គ្រប់ក្រុមទាំងអស់ត្រូវតែបិទភ្នែក)

២. ប្រើម៉ាស់ ឬក្រម៉ាដើម្បីបិតភ្នែកកុមារ

៣. ឲ្យចេកទៅកុមារទាំងអស់នៅក្នុងក្រុមទី១ ហើយឲ្យពួកគេបញ្ចុកក្រុមទី២ ដែលបានបិទភ្នែកនោះ។ ឲ្យចេកទៅកុមារទាំងអស់នៅក្នុងក្រុមទី៣ ហើយឲ្យពួកគេបញ្ចុកក្រុមទី៤ ដែលបានបិទភ្នែកនោះ។ ពួកគេមានពេល៥នាទីក្នុងការលេងល្បែងនេះ។

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងអាចបង្ហាញសេចក្តីសប្បុរសរបស់យើងទៅកាន់មិត្តភក្តិរបស់យើង ដោយការចែករំលែកអាហារ និងនំចំណីរបស់យើងបាន។

### ៤. ការណែនាំមេរៀន

តើមានប្អូនៗប៉ុន្មាននាក់ធ្លាប់ទទួលបានកាដូរខ្លះ? នៅពេលយើងទទួលបានការដូរ ពីប៉ាម៉ាក់ ឬពីមិត្តភក្តិ តើ ប្អូនៗសប្បាយចិត្តដែរឬទេ? ចុះតើប្អូនធ្លាប់អោយកាដូរទៅនរណាម្នាក់ដែរឬទេ? ព្រះបានផ្តល់ឲ្យយើងនូវកាដូរដូចជាចំណីអាហារ សម្លៀកបំពាក់ ថ្នាំសង្កូវដើម្បីជួយយើងក្នុងការធំធាត់។ ព្រះចង់ ប្រើយើងដើម្បីបង្ហាញពីចិត្តសប្បុរសចំពោះអ្នកឯទៀតតាមវិធីជាច្រើនផងដែរ។ ថ្ងៃនេះ យើងនឹងឮពីរបៀប ដែលព្រះបានធ្វើការតាមរយៈស្តេចដាវីឌ ដើម្បីបង្ហាញចិត្តសប្បុរស ចំពោះអ្នកដែលគ្មាននរណាចាប់អារម្មណ៍។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

បន្ទាប់ពីស្ដេចសូលបានសុគត់នៅក្នុងសមរភូមិ ដាវីឌក៏បានក្លាយទៅជាស្ដេចបន្ទាប់របស់សាសន៍អ៊ីស្រាអែល។ លោកបានធ្វើការជំឈ្លាសវែជាច្រើន ដើម្បីធ្វើឲ្យប្រជាជាតិអ៊ីស្រាអែលមានកម្លាំង។ ព្រះបានប្រទានជ័យជម្នះដល់គាត់គ្រប់ទីកន្លែងដែលគាត់ទៅ។ ថ្ងៃមួយ ស្ដេចដាវីឌបាននឹកចាំពីមិត្តសំលាញ់របស់គាត់ យ៉ូណាថាន ជាកូនប្រុសរបស់ស្ដេចសូល ដែលបានសោយទិវង្គតក្នុងសមរភូមិជាមួយឪពុករបស់គាត់។ គាត់ចង់បង្ហាញចិត្តសប្បុរសចំពោះគ្រួសាររបស់យ៉ូណាថាន។

ស្ដេចភាគច្រើននឹងស្វែងរកកូនចៅរបស់ស្ដេចមុន ដើម្បីប្រហារជីវិតពួកគេ ដើម្បីកុំឱ្យមានការគំរាមកំហែងដល់រាជបល្ល័ង្ក។ ប៉ុន្តែ នោះមិនមែនជាកង្វល់របស់ស្ដេចដាវីឌទេ។ ផ្ទុយទៅវិញ គាត់ចង់បង្ហាញចិត្តសប្បុរសចំពោះយ៉ូណាថាន ដែលបានជួយជីវិតគាត់។

កូនប្រុសរបស់យ៉ូណាថានមានឈ្មោះថា មភីបូសែត។ គាត់បានធ្លាក់ខ្លួនពិការ ពេលគាត់រត់គេចខ្លួនជាមួយអ្នកបម្រើ បន្ទាប់ពីយ៉ូណាថាន និងសូលត្រូវគេសម្លាប់ក្នុងសមរភូមិ។ នៅពេលដែលគាត់ដឹងថាស្ដេចដាវីឌ ចង់ជួបគាត់ គាត់ប្រាកដជាមានការភ័យខ្លាចដល់ជីវិត។

ប៉ុន្តែស្ដេចដាវីឌបានផ្ដល់សេចក្ដីសប្បុរសដល់មភីបូសែត។ គាត់បានប្រគល់ទឹកដីទាំងអស់ដែលជាកម្មសិទ្ធិរបស់ ស្ដេចសូល និងក្រុមគ្រួសាររបស់លោកដល់មភីបូសែត។ គាត់ក៏ឲ្យមភីបូសែតអង្គុយនៅតុដែលត្រូវគេគោរព ដូចជាមភីបូសែតជាកូនរបស់ដាវីឌអ៊ីចឹង!

ស្ដេចដាវីឌបានបង្ហាញចិត្តសប្បុរសយ៉ាងខ្លាំងចំពោះមភីបូសែត ជាចៅរបស់សូល ដែលចង់សម្លាប់គាត់។ ស្ដេចដាវីឌមិនចាំបាច់មានចិត្តសប្បុរសចំពោះមភីបូសែតទេ ប៉ុន្តែគាត់បានបង្ហាញចិត្តសប្បុរស ដោយសារដាវីឌដឹងថានោះជាអ្វីដែលព្រះចង់ឲ្យគាត់ធ្វើ។ គាត់យល់ថាព្រះតែងតែមានចិត្តសប្បុរសចំពោះគាត់ជានិច្ច។

ព្រះក៏ចង់ប្រើយើងដើម្បីបង្ហាញចិត្តសប្បុរសចំពោះមនុស្សគ្រប់រូបក្នុងជីវិតរបស់យើងដែរ។ ព្រះបានចាត់ព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវឲ្យមកបង្ហាញយើងពីរបៀបប្រព្រឹត្តចំពោះអ្នកដទៃ ដោយសេចក្ដីស្រឡាញ់ និងសេចក្ដីសប្បុរស។ ពេលយើងធ្វើតាមគំរូរបស់ព្រះយេស៊ូវ យើងអាចមានចិត្តសប្បុរសនិងស្រឡាញ់ចំពោះអ្នកដទៃដូចគ្នាដែរ។

## ៦. សំនួរពិភាក្សា

១. តើស្ដេចដាវីឌបានស្វែងរកនរណា បន្ទាប់ពីគាត់បានក្លាយជាស្ដេចរបស់សាសន៍អ៊ីស្រាអែល? *(កូនចៅរបស់យ៉ូណាថាន)*

២. ហេតុអ្វីបានជាដាវីឌស្វែងរកបុគ្គលនោះ? *(ព្រោះគាត់ចង់បង្ហាញពីសេចក្ដីសប្បុរស)*

៣. តើសេចក្ដីសប្បុរសអ្វីខ្លះដែលដាវីឌបានធ្វើសម្រាប់បុគ្គលម្នាក់នោះ? *(បានប្រគល់ដីទាំងអស់ដែលជាកម្មសិទ្ធិរបស់សូលឲ្យគាត់វិញ ហើយអនុញ្ញាតឲ្យគាត់បរិភោគនៅតុរបស់ស្ដេចដូចជាកូនរបស់ស្ដេច)*។

៤. តើអ្នកអាចបង្ហាញចិត្តសប្បុរសចំពោះអ្នកជុំវិញខ្លួនបានដោយរបៀបណា? *(លើកទឹកចិត្តមិត្តភក្តិ ជួយអ្នកខ្វះខាត ធ្វើអំពើល្អ ទោះបីមិត្តមិនល្អចំពោះអ្នក ។ល។)*

**៧. ល្បែងកំសាន្ត «បង្ហាញពីសេចក្ដីសប្បុរស»**

សម្ភារៈដែលត្រូវការ៖ ក្រដាសរង្វាន់ ស្ករគ្រាប់ នំ ឬក៏ផ្លែឈើក៏បាន



១. គ្រូអាចសរសេរពាក្យនៅក្រដាសរង្វាន់ "ស្ករគ្រាប់២គ្រាប់" "នំ៥កញ្ចប់" ឬក៏ "ស្ករគ្រាប់ដប់" ។(ប្រសិនបើអាច "ចេកពីរផ្លែ" "ឪឡឹក៥" ឬក៏ល្ហុង១០" ប្រសិន បើគាត់មាននៅក្នុងភូមិ)

២. មូលក្រដាសដែលបានសរសេររួចនោះ ហើយដាក់វានៅក្នុងប្រអប់មួយ។

៣. ឲ្យកុមារស្មគ្រ័ចិត្តឡើងមកចាប់ក្រដាសមួយ។ នៅពេលដែលគេទទួលបានរង្វាន់សូមលើកទឹកចិត្តពួកគេឲ្យចែករំលែកដល់មិត្តភក្តិ។

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងអាចចែករំលែកបានមិនថា យើងមានតិចឬ ក៏ច្រើនក៏ដោយ។ ការបង្ហាញសេចក្ដីសប្បុរសគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះព្រះតែងតែមានសេចក្ដីសប្បុរសចំពោះយើង។

**៨. ខគម្ពីរចងចាំ**

**១យូហាន ៤៖១២** *"គ្មានអ្នកណាដែលឃើញព្រះឡើយ តែបើយើងស្រឡាញ់គ្នាទៅវិញទៅមក នោះព្រះទ្រង់គង់នៅក្នុងយើង ហើយសេចក្ដីស្រឡាញ់របស់ទ្រង់ បានពេញខ្នាតក្នុងយើងដែរ។"*

**៩. ហាត្ថកម្ម «ដាវីឌមានចិត្តសប្បុរសចំពោះមភីបូសែត»**

សម្ភារៈដែលត្រូវការ៖ សូមបោះពុម្ពរូបភាពរបស់មភីបូសែត កន្ត្រៃ កូល័រ ការបិត ដងឈើការ៉េម



១. កាត់រូបរបស់មភីបូសែតចេញមក

២. កាត់រូបនៅបរិវេនដៃ ដើម្បីឲ្យយើងអាចបិតរូបដៃនោះភ្ជាប់ជាមួយនឹងបន្ទះឈើបាន

៣. បិទបន្ទះឈើជាមួយរូបរបស់មភីបូសែត ដើម្បីបញ្ជាក់ថាគាត់ជាមនុស្សពិការ។

៤. សូមពន្យល់កុមារថា ប្រសិនបើស្ដេចដាវីឌមិនបានបង្ហាញពីសេចក្ដីសប្បុរសរបស់គាត់ចំពោះមភីបូសែតទេនោះ ជីវិតរបស់មភីបូសែតច្បាស់ជារស់នៅដោយក្រៀមក្រំនិងលំបាកដោយសារតែគាត់ជាមនុស្សពិការមិនអាចធ្វើកិច្ចការងារបាន។ ស្ដេចដាវីឌបានបង្ហាញសេចក្ដីសប្បុរសទៅកាន់មភីបូសែត ដោយសារតែគាត់បានដឹងថាព្រះតែងតែសប្បុរសចំពោះគាត់ជានិច្ច។ ព្រះក៏តែងតែសប្បុរសចំពោះពួកយើងជានិច្ចដែរ! យើងគួរតែបង្ហាញសេចក្ដីសប្បុរសទៅកាន់អ្នកដែលនៅជុំវិញខ្លួនយើងផងដែរ។

**១០. ចំរៀង** (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

ដោយព្រោះតែទង្វើចុងក្រោយរបស់ព្រះគឺជាសេចក្ដីស្រលាញ់ និងសេចក្ដីសប្បុរស- ដោយសុគត លើឈើឆ្កាងសម្រាប់យើង- ដូច្នេះយើងក៏បានរួចចេញពីសេចក្ដីស្លាប់។ សេចក្ដីសប្បុរសគឺវាមិនត្រឹមតែធ្វើល្អប៉ុណ្ណោះនោះទេ។ សូមអានព្រះគម្ពីរ **២ សាំយូអែល៩៖៧**។ តើភាពយុត្តិធម៌និងសេចក្ដីសុចរិត មានចំណែកអ្វីនៅក្នុងសេចក្ដីសប្បុរស? តើទំនាក់ទំនងរបស់យើងនឹងក្លាយទៅជាយ៉ាងណា ប្រសិនបើយើងធ្វើតែអ្វីដែល "ត្រឹមត្រូវ" និង "ត្រូវ" សម្រាប់អ្នកដទៃនោះ?អរគុណព្រះជាម្ចាស់ដែលបានបង្ហាញឲ្យយើងឃើញតាមរបស់ព្រះយេស៊ូវអំពីសេចក្ដីសប្បុរសដែលយើងអាចធ្វើបាននិងចែករំលែកសេចក្ដីសប្បុរសរបស់ទ្រង់ទៅកាន់អ្នកដទៃនិងចែកចាយពីសេចក្ដីស្រលាញ់របស់ទ្រង់ផងដែរ។

# ដាវីឌមានចិត្តសប្បុរសចំពោះមភីបូ៍សែត





# ដាវីឌមានចិត្តសប្បុរសចំពោះមេភីបូសែត



សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________________________________

______________________________________________________

______________________________________________________